នស/រកម/០៤៩៨/០៥

រដ្ឋសភា
ចូល
លេខ.......
ថ្ងៃទី.......ម៉ោង.......
បញ្ជូនទៅ.......

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស_៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៥_៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_០៨៩៧_១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស_រកម_០១៩៦_០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស_រកម_១១៩៧_០៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស_រកម_១២៩៧_០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និង របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ធ្វើវិសោធនកម្មលើ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

## បន្ថែមទៅលើ

## ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

# ឧបសម្ព័ន្ធ ក

## សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## ថ្ងៃអាទិត្យ ទី ២៦ កក្កដា ឆ្នាំ ១៩៩៨

## ប្រតិទិន

បង្កើតការិយាល័យចុះឈ្មោះបោះឆ្នោត........................................ ២០ មេសា ១៩៩៨

ចាប់ផ្តើមចុះឈ្មោះអ្នកបោះឆ្នោត.................................................. ២៧ មេសា ១៩៩៨

បញ្ចប់ចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនិងបេក្ខជនឈរឈ្មោះបោះឆ្នោត.........
....................................................................... ០៧ ឧសភា ១៩៩៨

បិទផ្សាយបញ្ជីដំបូងនៃបេក្ខជនឈរឈ្មោះបោះឆ្នោតនិងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត.....
....................................................................... ០៨ ឧសភា ១៩៩៨

បញ្ចប់ការចុះឈ្មោះអ្នកបោះឆ្នោត............................................ ២៣ ឧសភា ១៩៩៨

បិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការ.............. ១២ មិថុនា ១៩៩៨

ចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោត........................................ ២៥ មិថុនា ១៩៩៨

បិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការនិងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ...២៥ មិថុនា ១៩៩៨

បិទផ្សាយបញ្ជីឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោត....................... ២៦ មិថុនា ១៩៩៨

បញ្ចប់យុទ្ធនាការឃោសនាបោះឆ្នោត........................................... ២៤ កក្កដា ១៩៩៨

ថ្ងៃបោះឆ្នោត........................................................................ ២៦ កក្កដា ១៩៩៨

# ឧបសម្ព័ន្ធ ១

## សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## ថ្ងៃអាទិត្យ ២៦ ខែកក្កដា ឆ្នាំ ១៩៩៨

ក្រោយពីច្បាប់នេះចូលជាធរមាន ជនណាដែលមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានសិទ្ធិចុះឈ្មោះជាបេក្ខជនជាបណ្ដោះអាសន្នបាន ដោយពុំចាំបាច់មានប័ណ្ណបោះឆ្នោត ។ ក្រោយពីបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត សាមីខ្លួនត្រូវបញ្ជូនលេខប័ណ្ណបោះឆ្នោតរបស់ខ្លួនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដប់ប្រាំ(១៥)ថ្ងៃយ៉ាងយូរ ក្រោយពីថ្ងៃប្រកាសបិទបញ្ជីបោះឆ្នោតដំបូងតាមការិយាល័យចុះឈ្មោះរបស់ខ្លួន ដើម្បីបំពេញសុពលភាពជាបេក្ខជន។

លក្ខខណ្ឌនៃការស្នាក់នៅជាអចិន្ត្រៃយ៍រយៈពេលមួយឆ្នាំឬមួយខែរបស់បេក្ខជនដែលកំណត់ក្នុងមាត្រា ៣៣ ចំណុច ៤ និងមាត្រា ១៣៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មិនត្រូវបានយកមកអនុវត្តទេ ។

ការចុះបញ្ជីគណបក្សនយោបាយនិងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រជាផ្លូវការ ត្រូវបញ្ចប់យ៉ាងយូរប៉ែតសិប(៨០)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង :

-រយៈពេលប្ដឹងតវ៉ាឬជំទាស់ត្រូវកំណត់ត្រឹមបី (៣)ថ្ងៃយ៉ាងយូរ ។

-គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្ដឹងតវ៉ាឬជំទាស់នេះ ក្នុងរយៈពេលមួយ (១)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

-ក្នុងករណីអ្នកប្ដឹងតវ៉ាឬជំទាស់នៅពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ជននោះឬអ្នកតំណាងអាចប្ដឹងតវ៉ាឬជំទាស់ជាលាយលក្ខអក្សរទៅគណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោតក្នុងរយៈពេលបី (៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មការ ឃុំ សង្កាត់ រៀបចំការបោះឆ្នោត ។

គណៈកម្មការ ខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្ដឹងតវ៉ាឬជំទាស់នេះក្នុងរយៈពេលប្រាំ (៥)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលពាក្យបណ្ដឹង ។

-ក្នុងករណីដែលអ្នកប្ដឹងតវ៉ា ឬជំទាស់ នៅពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោត បេក្ខជននោះឬអ្នកតំណាងអាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលបី (៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្ដឹងតវ៉ាឬជំទាស់នេះ ក្នុងរយៈពេលប្រាំ (៥)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

-ក្នុងករណីដែលអ្នកប្ដឹងតវ៉ាឬជំទាស់នៅពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បេក្ខជននោះឬអ្នកតំណាងអាចប្ដឹងតវ៉ាឬជំទាស់ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលពីរ (២)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចលើបណ្ដឹងតវ៉ាឬជំទាស់នេះ ក្នុងរយៈពេលប្រាំ(៥)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ៕

# ច្បាប់បន្ថែម

## នៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រាតែមួយ.-**

មាត្រា ១៣៧ ស្ទួន.- ដើម្បីការបោះឆ្នោតនៅថ្ងៃអាទិត្យ ទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨ កាលបរិច្ឆេទ រយៈពេលនិងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៣.៣៧.៣៨.៤៨.៦៤.៦៥.៦៦ និង១៣៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ ក និង ខ ដែលមានភ្ជាប់មកជាមួយនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨
ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ហត្ថលេខា | ហត្ថលេខា |
| អ៊ុង ហួត | ហ៊ុន សែន |

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា
ស ខេង យូ ហុកគ្រី

លេខ : ៩៩ ចប
ដើម្បីចម្លងចែក
រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ មេសា ឆ្នាំ១៩៩៨
[illegible]